## ៨-១-៧-២-ជយន្តោ

**ជយន្តោ ពោធិយាមូលេ សក្យានំ នន្ទិវឌ្ឍនោ ឯវំ តុំ វិជយោ ហោហិ ជយស្សុ ជយមង្គលេ អបរា ជិត បល្លង្កេ សីសេ បថវិបោក្ខរេ អភិសេកេ សព្វពុទ្ធានំ អគ្គប្បត្តោ បមោទតិ**

*ព្រះសម្មាសម្ពុទ្ធទ្រង់ញុំាងសេចក្តី ត្រេកអរនៃសក្យៈទាំងឡាយឲ្យចម្រើន ព្រះអង្គទ្រង់ឈ្នះមារហើយបានដល់នូវភាពជា បុគ្គលប្រសើរបំផុត ទ្រង់រីករាយ (ចំពោះធម៌ដែលព្រះអង្គត្រាស់ដឹង) លើអបរា ជិតបល្ល័ង្ក ជាជយមង្គល ទៀបគល់ពោធិព្រឹក្សត្រង់ផ្ចិតផែនដី ដូចជាស្ទឹកឈូក ជាទីអភិសេកនៃ ព្រះ ពុទ្ធ គ្រប់ព្រះអង្គ(យ៉ាងណាមិញ) សូមឲ្យអ្នកជាបុគ្គល មានជំនះ ឈ្នះមារ (អស់សត្រូវ) យ៉ាងនោះឯង,*

**-សុនក្ខត្តំ សុមង្គលំ សុបភាតំ សុហុដ្ឋិតំ សុខណោ សុមុហុត្តោ ច សុយិដ្ឋំ ព្រហ្មចារីសុ.** *ពេលណាដែលសត្វទាំងឡាយប្រព្រឹត្តល្អដោយ កាយ វាចា ចិត្ត ពេលនោះឈ្មោះថា ជានក្ខត្តឫក្សល្អ ជាមង្គលល្អ ជាពេលភ្លឺស្វាងល្អ ជាពេលនៃអរុណរះល្អ ជាខណៈល្អ ជាយាមល្អ ទានដែលបុគ្គលបានបូជាហើយដល់ព្រហ្មចារីបុគ្គលទាំងឡាយក្នុងពេលនោះ ឈ្មោះថាជាគ្រឿងបូជាល្អ,*

**-បទក្ខិណំ កាយកម្មំ វាចាកម្មំ បទក្ខិណំ បទក្ខិណំ មនោកម្មំ បណិធីតេ បទក្ខិណា,** *ក្នុងថ្ងៃនោះ កាយកម្មក៏ឈ្មោះថានាំឲ្យមានសេចក្តីចំរើន វចីកម្ម មនោកម្ម ក៏ឈ្មោះថានាំឲ្យមាន សេចក្តីចំរើន សេចក្តីប្រាថ្នាទាំងឡាយរបស់អ្នកទាំងនោះ ក៏ឈ្មោះថានាំឲ្យមានសេចក្តីចំរើន,*

**-បទក្ខិណានិ កត្វាន លភន្តត្ថេ បទក្ខិណេ,** *បុគ្គលដែលបានធ្វើនូវ កាយកម្ម វិចីកម្ម មនោកម្ម គួរដល់សេចក្តីចំរើនយ៉ាងនេះហើយ ក៏រមែងបាននូវប្រយោជន៍ ដ៏ចំរើនទាំងឡាយ៕*

វិលទៅរកទំព័រចាស់វិញ ដោយចុចលើព្រួញ “ ← “ ដែលនៅ កៀនកញ្ចក់ ខាងលើ និងខាងឆ្វេង។